ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមព្រហ្មទណ្ឌ

-លេខ ៦១៣ "ត"
ចុះថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២១
-**សំណុំរឿងព្រហ្មទណ្ឌ**
លេខ ៥១៥៧
ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩
-**ជំនុំជម្រះលេខ** ៦៣៣១
ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០២០

តាងនាមប្រជារាស្ត្រខ្មែរ
សាលាដំបូងរាជធានីភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ វេលាម៉ោង ៨:៣០ នាទីព្រឹក នៅសាលសវនាការទី៦ ដោយមានសមាសភាព ៖

ចៅក្រមជំនុំជម្រះ

-លោក [redacted] ជាអនុប្រធានសាលាដំបូងរាជធានីភ្នំពេញ

តំណាងអយ្យការ

-លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងរាជធានីភ្នំពេញ

ក្រឡាបញ្ជីសវនាការ

-លោក [redacted] ក្រឡាបញ្ជីសាលាដំបូងរាជធានីភ្នំពេញ

ដើម្បីជំនុំជម្រះលើសំណុំរឿងព្រហ្មទណ្ឌលេខ ៥១៥៧ ចុះថ្ងៃទី០៦ ខែសីហា ឆ្នាំ២០១៩ ដែលមាន ៖

-ជនជាប់ចោទឈ្មោះ [redacted] **ភូ វិរុធ** ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ មុនរបរលក់ដូរ ទីកន្លែងកំណើត[redacted] ក្រុងភ្នំពេញ ទីលំនៅបច្ចុប្បន្នស្នាក់នៅផ្ទះលេខ៩៨ ផ្លូវលេខ៨០ ភូមិ៣៣ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ ប្រពន្ធឈ្មោះ [redacted] **សុភាព** មានកូនចំនួន០៣នាក់ ឪពុកឈ្មោះ [redacted] **ឡៅ** (ស្លាប់) ម្តាយឈ្មោះ [redacted] **ផាន** (ស្លាប់) ជានីតិជន ទោសពីមុនគ្មាន ។ (ក្រៅឃុំ)

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ មានអាសយដ្ឋាននៅការិយាល័យក្រុមមេធាវីភ្នំពេញ កម្ពុជា នៅផ្ទះលេខ១៥B ផ្លូវលេខ៣៧១ ភូមិត្រពាំងឈូក សង្កាត់ទឹកថ្លា ខណ្ឌសែនសុខ រាជធានីភ្នំពេញ ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ មានអាសយដ្ឋាននៅការិយាល័យក្រុមហ៊ុនមេធាវី **អិល អេស ភី** នៅផ្ទះលេខ២៦C ផ្លូវលេខ២១៣ សង្កាត់វាលវង់ ខណ្ឌ៧មករា រាជធានីភ្នំពេញ ។

ជាប់ចោទពីបទ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

-**ដើមបណ្តឹងរដ្ឋប្បវេណី** និងជា**ជនរងគ្រោះ**ឈ្មោះ [redacted] **លីណា** ភេទស្រី អាយុ៤៩ឆ្នាំ កើតឆ្នាំ១៩៧២ ជាតិខ្មែរ មានទីលំនៅបច្ចុប្បន្ននៅផ្ទះលេខ២E$_1$ ផ្លូវលេខ៣១២ ភូមិ៥ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ មានការិយាល័យនៅផ្ទះលេខ៥៣៤ អឺសូឡ ផ្លូវលេខ៥៩៨ សង្កាត់ច្រាំងចំរេះ១ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

អង្គហេតុនៃរឿងមានដូចតទៅ

កាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **ភូ វិរុធ** បានខ្ចីប្រាក់ពីឈ្មោះ [redacted] **លីណា** ចំនួន ១៥.000 (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក តាមរយៈកិច្ចសន្យាដាក់ធានា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០១៣ ហើយជនត្រូវចោទបានដាក់តម្កល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២១០២១១០១០៣៥៣ ចុះថ្ងៃទី ២៧ ខែកក្កដា ឆ្នាំ២០១១ ឱ្យទៅឈ្មោះ [redacted] **លីណា** ដើម្បីផ្តល់ជាទំនុកចិត្ត ។ ក្រោយមកនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤

ឈ្មោះ [redacted] ភូរិវុធ បានខ្ចីប្រាក់ពីជនរងគ្រោះចំនួន ២៥.000 (ពីរម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ហើយសន្យាសងប្រាក់ទាំងមុននិងក្រោយសរុបចំនួន ៤0.000 (បួនម៉ឺន) ដុល្លារអាមេរិក និងសន្យាផ្តល់ប្រាក់ចំណេញដល់ជនរងគ្រោះ តែក្រោយពីទទួលបានប្រាក់ហើយ ជនត្រូវចោទមិនបានសងប្រាក់តាមសន្យា ហើយបិទទូរស័ព្ទនិងទូរស័ព្ទចូលមិនព្រមលើក គេចវេះពីការទទួលខុសត្រូវ ។

-បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី២៩ ខែកក្កដា ឆ្នាំ២0១៩ របស់ឈ្មោះ [redacted] លីណា ។

-បានឃើញដីកាសន្និដ្ឋានបញ្ជូនរឿងឱ្យស៊ើបសួរលេខ ១៩២៩ អ.យ.ខ ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២0២0 របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ ។

-បានឃើញដីកាបង្គាប់ឱ្យចូលខ្លួនលេខ ៤0១ "ឆ"ព្រ.ទ ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២0២0 របស់ចៅក្រមស៊ើបសួរ ។

-បានឃើញដីកាសម្រេចដាក់ជនត្រូវចោទឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យតាមផ្លូវតុលាការលេខ៥៥២៧ "ឆ"ដ.ព.ស ចុះថ្ងៃទី១៤ ខែកក្កដា ឆ្នាំ២0២0 របស់ចៅក្រមស៊ើបសួរ ។

-បានឃើញដីកាសន្និដ្ឋានស្តាពរលេខ៥៩១0 អ.យ.ខ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២0២0 របស់តំណាងអយ្យការអមសាលាដំបូងរាជធានីភ្នំពេញ។

-បានឃើញដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៧៥៤0 "ឆ"ដ.ដ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២0២0 របស់ចៅក្រមស៊ើបសួរសាលាដំបូងរាជធានីភ្នំពេញ ។

នាពេលសវនាការ

-តាមអំណានចម្លើយជនជាប់ចោទឈ្មោះ [redacted] ភូរិវុធ បានឆ្លើយនៅដំណាក់កាលអយ្យការនិងចៅក្រមស៊ើបសួរប្រហាក់ប្រហែលគ្នាថា ៖ ខ្លួនសុំបដិសេធនូវការចោទប្រកាន់របស់តំណាងអយ្យការទាំងស្រុង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ។ នៅថ្ងៃទី0៦ ខែតុលា ឆ្នាំ២0១៣ ខ្លួនបានខ្ចីចងការប្រាក់ពីឈ្មោះ [redacted] លីណា ចំនួនប្រាក់ដើម ១៥.000 ដុល្លារ ដោយគិតតម្លៃការប្រាក់ចំនួន ៣% ក្នុង១ខែដែលស្មើ ៤៥0 ដុល្លារ ដោយបានធ្វើកិច្ចសន្យាចុះថ្ងៃទី0៦ ខែតុលា ឆ្នាំ២0១៣ ហើយការអនុវត្តកិច្ចសន្យាចាប់ពីថ្ងៃទី0៨ ខែតុលា ឆ្នាំ២0១៣ តទៅ ។ ក្នុងការខ្ចីប្រាក់នេះ គឺខ្លួនបានដាក់ធានានូវវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១0២១១0១-0៣៥៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២0១១ របស់ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មសំណង់ និងសុរិយោដី ខេត្តតាកែវ ។ ចាប់ពីពេលធ្វើកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី0៦ ខែតុលា ឆ្នាំ២0១៣មក ខ្លួនបានអនុវត្តតាមកិច្ចសន្យាដោយបានបង់ការប្រាក់ឱ្យភាគីលោកស្រី [redacted] លីណា ជារៀងរាល់ខែមិនដែលអាក់ខានទេ គឺបង់រហូតដល់អំឡុងខែកុម្ភៈ ឬខែមីនា ឆ្នាំ២0១៩ បន្ទាប់មកខ្លួនក៏បានធ្លាក់ខ្លួនមានជំងឺប្រចាំកាយ (ជំងឺថ្លើម) ពេលធ្លាក់ខ្លួនឈឺនោះខ្លួនពុំបានប្រកបអាជីវកម្មដូចមុន ហើយប្រាក់ដែលមានត្រូវចំណាយព្យាបាលជំងឺជាហេតុធ្វើឱ្យខ្លួនមិនអាចបង់ការប្រាក់ឱ្យគាត់បានតាមកិច្ចសន្យា ហើយឈ្មោះ [redacted] លីណា ក៏បានប្តឹងខ្លួនទៅសមត្ថកិច្ចនគរបាលរាជធានីភ្នំពេញ ហើយខ្លួនបានសុំអង្វរគាត់សុំពន្យារពេលសងតែគាត់ពុំព្រមឡើយ។ ចំពោះឈ្មោះ [redacted] លីណា ចោទប្រកាន់ខ្លួនថាគេចវេះពុំទទួលទូរស័ព្ទនោះគឺពុំពិតឡើយ ព្រោះពេលនោះខ្លួនបានទៅព្យាបាលជំងឺនៅប្រទេសវៀតណាម ហើយទូរស័ព្ទគឺកូនខ្លួនជាអ្នកទទួលជំនួស ហើយកូនខ្លួនក៏បានប្រាប់ទៅឈ្មោះ [redacted] លីណា ដែរថាខ្លួនទៅព្យាបាលជំងឺ ។ នៅក្នុងរឿងនេះឈ្មោះ [redacted] លីណា បានប្តឹងខ្លួនមានសំណុំរឿងព្រហ្មទណ្ឌចំនួន២ គឺសំណុំរឿងព្រហ្មទណ្ឌលេខ ៥១៥៧ ចុះថ្ងៃទី0៦ ខែសីហា ឆ្នាំ២0១៩ ដែលមានលោក [redacted] ជាព្រះរាជអាជ្ញាទទួលបន្ទុក និងសំណុំរឿងព្រហ្មទណ្ឌលេខ ១៤៥0 ចុះថ្ងៃទី0៥ ខែមីនា ឆ្នាំ២0១៩ ដែលមានលោក [redacted] ជាព្រះរាជអាជ្ញាទទួលបន្ទុក ។ នៅក្នុងសំណុំរឿងនេះខ្លួនពុំបានប្រព្រឹត្តអំពើឆបោកប្រាក់ដូចការចោទប្រកាន់ទេ គឺជាការខ្ចីចងការប្រាក់មានការដាក់បញ្ចាំអចលវត្ថុដើម្បីធានាសំណងការខូចខាតដល់ម្ចាស់បំណុលផង ។ ម្យ៉ាងទៀតការអាក់ខានមិនបានសងគាត់គឺដោយសារខ្លួនមានជំងឺប្រចាំកាយ និងពុំបានប្រកបអាជីវកម្ម គ្មានប្រាក់សងគាត់ ហើយប្រាក់នោះខ្លួនសុំសងតែប្រាក់ដើមចំនួន ១៥.000 ដុល្លារ ចំពោះការប្រាក់និងជំងឺចិត្ត ខ្លួនសុំម្ចាស់បំណុលចោល និងសំណូមពរសូមឱ្យតុលាការលើកលែងចោទប្រកាន់ខ្លួនឱ្យរួចផុតពីបទចោទ ។ ចំពោះប្រាក់ដើមចំនួន ១៥.000 ដុល្លារ នេះខ្លួនមានលទ្ធភាពសងក្នុង១ខែ ចំនួន៥00 ដុល្លារ ដោយសុំសងចាប់ពីខែ

សីហា ឆ្នាំ២០២០ នេះតទៅ ។

-**តាមអំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ [redacted] លីណា** បានឆ្លើយនៅដំណាក់កាលអយ្យការ និងចៅក្រមស៊ើបសួរថា ៖ នៅថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ឈ្មោះ [redacted] **ភូវិវុធ** បានមកខ្ចីចងការប្រាក់ពីខ្លួនទ្រព្រាក់ដើមចំនួន១៥.000 ដុល្លារ ក្នុងអត្រាការប្រាក់ ៥% ក្នុងមួយខែ ។ នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ឈ្មោះ [redacted] **ភូវិវុធ** បានមកខ្ចីប្រាក់បន្ថែមពីខ្លួនចំនួន ២.000 ដុល្លារ ទៀត ហើយនៅចុងឆ្នាំ២០១៤ ឈ្មោះ [redacted] **ភូវិវុធ** បានសងប្រាក់ដើមមកខ្លួនចំនួន ២.000 ដុល្លារ ប៉ុណ្ណោះ ដោយចាប់ពីដើមឆ្នាំ២០១៥រហូតដល់បច្ចុប្បន្ននេះ គឺឈ្មោះ [redacted] **ភូវិវុធ** ពុំបានសងប្រាក់ដើម និងកម្រៃការប្រាក់មកឲ្យខ្លួនឡើយ គឺគាត់បានគេចវេះពីខ្លួន សូម្បីទំនាក់ទំនងតាមទូរស័ព្ទក៏គាត់មិនទទួលទូរស័ព្ទឡើយ ។ នៅក្នុងការខ្ចីប្រាក់នេះឈ្មោះ [redacted] **ភូវិវុធ** បានដាក់ធានានូវវិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ ២១០២១១០១-0៣៥៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ដល់ខ្លួនផងដែរ ។ នៅក្នុងរឿងនេះខ្លួនសំណូមពរ៖ សូមផ្តន្ទាទោសឈ្មោះ [redacted] **ភូវិវុធ** តាមច្បាប់ , ទាមទារប្រាក់ខូចខាតចំនួន ១៥.000 ដុល្លារ និងទាមទារជំងឺចិត្ត ការខាតបង់ពេលវេលាព្រមទាំងថ្លៃជួលមេធាវីសរុបចំនួន ១៨0.000.000 រៀល ។ ខ្លួនសុំបញ្ជាក់បន្ថែមថា ខ្លួនមានសាក្សីដឹងឮក្នុងរឿងនេះមានឈ្មោះ [redacted] **ចំរើន** ភេទស្រី មានទីលំនៅផ្ទះលេខ ៧៥E0 ផ្លូវលេខ២៧១ សង្កាត់ទឹកល្អក់ទី៣ ខណ្ឌទួលគោក រាជធានីភ្នំពេញ ឈ្មោះ [redacted] **ហឿន** ភេទប្រុស នៅភូមិចំប៉ា ឃុំសូភី ស្រុកបាទី ខេត្តតាកែវ និងឈ្មោះ [redacted] **ថុស** ភេទប្រុស ជាមេឃុំសូភី ស្រុកបាទី ខេត្តតាកែវ ។

សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា ៖ ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងឃើញថាកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** បានខ្ចីប្រាក់ពីឈ្មោះ [redacted] **លីណា** ចំនួន **១៥.000 (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក** តាមរយៈកិច្ចសន្យាដាក់ធានា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ។ ជនជាប់ចោទទទួលស្គាល់ថាខ្លួនបានជំពាក់ប្រាក់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនតែ ១៥.000 ដុល្លារអាមេរិកប៉ុណ្ណោះ ។ តំណាងអយ្យការយល់ឃើញថាចម្លើយរបស់គូភាគីមានភាពស៊ីសង្វាក់គ្នា ដូចនេះសុំឱ្យតុលាការឱ្យជនជាប់ចោទរួចផុតពីបទចោទ ។

សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់ពួកខ្លួនពិតជាបានខ្ចីប្រាក់ពីជនជាប់ចោទចំនួន១៥.000ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៣%ក្នុងមួយខែ ហើយកូនក្តីពួកខ្លួនទទួលស្គាល់នូវប្រាក់ដែលជំពាក់ជនជាប់ចោទដោយមានដាក់ទ្រព្យធានាផងដែរ តែកូនក្តីពួកខ្លួនពុំមានចេតនាគេចវេះនោះទេ ។ ក្នុងនាមពួកខ្លួនជាមេធាវី ពួកខ្លួនស្នើសុំឱ្យតុលាការមេត្តាឱ្យកូនក្តីពួកខ្លួនរួចផុតពីបទចោទ ។

សំដីចុងក្រោយរបស់ជនជាប់ចោទ ៖ គ្មាន ។

-ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ

-ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់តំណាងអយ្យការ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ

-ក្រោយពីបានពិនិត្យលើឯកសារ ភស្តុតាងនានា

-ក្រោយពីបានពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

សំអាងហេតុ

១-ជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** ភេទប្រុស អាយុ ៥0ឆ្នាំ ជាតិខ្មែរ ត្រូវបានតំណាងអយ្យការដាក់ឱ្យស្ថិតនៅ

ក្រោមការពិនិត្យពីបទ **ឆបោក** តាមដីកាសន្និដ្ឋានស្តាពរលេខ៥៩១០ អ.ឃ.ខ ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២០ ហើយត្រូវបានចៅក្រមស៊ើបសួរបញ្ជូនទៅជំនុំជម្រះ តាមដីកាសម្រេចបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ ៧៥៤៦ "ឆ"ដ.ដ ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២០ ។

២-តាមចម្លើយរបស់ជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** និងដើមបណ្តឹងរដ្ឋប្បវេណីនិងជាជនរងគ្រោះឈ្មោះ [redacted] លីណា និងកិច្ចសន្យាដាក់ធានា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ព្រមទាំងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងមានភាពស៊ីសង្វាក់គ្នាបង្ហាញថាកាលពីថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ នៅរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** ពិតជាបានខ្ចីប្រាក់ពីដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] **លីណា** ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ដោយបានដាក់តម្កល់វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនវត្ថុលេខ២១០២១០១០៣៥៣ ចុះថ្ងៃទី២៧ ខែកក្កដា ឆ្នាំ២០១១ ដើម្បីធានាបំណុលប្រាកដមែន ក្រោយពីជនជាប់ចោទបានសងនូវការប្រាក់បានមួយចំនួនឱ្យដើមបណ្តឹងរដ្ឋប្បវេណី ក៏បានអាក់ខានសងការប្រាក់ឱ្យដើមបណ្តឹងរដ្ឋប្បវេណីតែម្តង ។

ចំណែកអង្គហេតុនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ ដើមបណ្តឹងរដ្ឋប្បវេណីបានលើកឡើថាជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** បានមកខ្ចីប្រាក់បន្ថែមពីខ្លួនចំនួន ២.០០០ ដុល្លារ ទៀត ហើយនៅចុងឆ្នាំ២០១៤ ឈ្មោះ [redacted] **ភូវិវុធ** បានសងប្រាក់ដើមមកខ្លួនចំនួន ២.០០០ ដុល្លារ ប៉ុណ្ណោះ ដោយចាប់ពីដើមឆ្នាំ២០១៥រហូតដល់បច្ចុប្បន្ននេះ គឺឈ្មោះ [redacted] **ភូវិវុធ** ពុំបានសងប្រាក់ដើម និងការប្រាក់មកឱ្យខ្លួនឡើយ គឺគាត់បានគេចវេះពីខ្លួន សូម្បីទំនាក់ទំនងតាមទូរស័ព្ទក៏គាត់មិនទទួលទូរស័ព្ទឡើយ ។ តែជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** បានឆ្លើយថាខ្លួនសុំបដិសេធចោលនូវការចោទប្រកាន់របស់តំណាងអយ្យការទាំងស្រុង ព្រោះខ្លួនពុំបានប្រព្រឹត្តដូចការចោទប្រកាន់ទេ ហើយខ្លួនទទួលស្គាល់តែប្រាក់ជំពាក់ចំនួន ១៥.០០០ (មួយម៉ឺនប្រាំពាន់) ដុល្លារអាមេរិក ប៉ុណ្ណោះ ។

៣-តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំថា៖ ក្រោយពីបានស្តាប់អំណានចម្លើយជនជាប់ចោទ អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី និងភស្តុតាងនានាដែលមាននៅក្នុងសំណុំរឿងឃើញថាកាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ នៅរាជធានីភ្នំពេញ ជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** បានខ្ចីប្រាក់ពីឈ្មោះ [redacted] **លីណា** ចំនួន ១៥.០០០ (**មួយម៉ឺនប្រាំពាន់ដុល្លារអាមេរិក** តាមរយៈកិច្ចសន្យាដាក់ធានា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០១៣ ។ ជនជាប់ចោទទទួលស្គាល់ថាខ្លួនបានជំពាក់ប្រាក់ដើមបណ្តឹងរដ្ឋប្បវេណីចំនួនតែ ១៥.០០០ ដុល្លារអាមេរិកប៉ុណ្ណោះ ។ តំណាងអយ្យការយល់ឃើញថាចម្លើយរបស់គូភាគីមានភាពស៊ីសង្វាក់គ្នា ដូចនេះសុំឱ្យតុលាការឱ្យជនជាប់ចោទរួចផុតពីបទចោទ តុលាការគប្បីពិចារណា ។

៤-លោក [redacted] ជាមេធាវីការពារសិទ្ធិឱ្យជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានការពារថា៖ កូនក្តីរបស់ពួកខ្លួនពិតជាបានខ្ចីប្រាក់ពីជនជាប់ចោទចំនួន១៥.០០០ដុល្លារអាមេរិក ក្នុងអត្រាការប្រាក់ ៣%ក្នុងមួយខែ ហើយកូនក្តីពួកខ្លួនទទួលស្គាល់នូវប្រាក់ដែលជំពាក់ជនជាប់ចោទដោយមានដាក់ទ្រព្យធានាផងដែរ តែកូនក្តីពួកខ្លួនពុំមានចេតនាគេចវេះនោះទេ ។ ក្នុងនាមពួកខ្លួនជាមេធាវី ពួកខ្លួនស្នើសុំឱ្យតុលាការមេត្តាឱ្យកូនក្តីពួកខ្លួនរួចផុតពីបទចោទ តុលាការគប្បីពិចារណា ។

៥-តាមអំណានចម្លើយរបស់ជនជាប់ចោទ ដើមបណ្តឹងរដ្ឋប្បវេណី កិច្ចសន្យាដាក់ធានា ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ ២០១៣ សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ សេចក្តីសន្និដ្ឋានការពាររបស់មេធាវីការពារឱ្យជនជាប់ចោទ ព្រមទាំងភស្តុ-តាងនានាដែលមាននៅក្នុងសំណុំរឿងបង្ហាញឱ្យឃើញថាអង្គហេតុខាងលើជាវិវាទរដ្ឋប្បវេណីរវាងជនជាប់ចោទនិងដើម-បណ្តឹងរដ្ឋប្បវេណីវាពុំមែនជាវិវាទព្រហ្មទណ្ឌទេ ហើយជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ** ពុំបានប្រព្រឹត្តបទល្មើសដូចការចោទប្រកាន់របស់តំណាងអយ្យការខាងលើឡើយ ដោយសារអវត្តមាននៃបទល្មើស ឬជនជាប់ចោទពុំមានកំហុស នេះបានបង្ហាញពីនត្ថិភាពនៃធាតុផ្សំនៃបទល្មើសគ្រប់គ្រាន់ ដូចនេះតុលាការគប្បីឱ្យជនជាប់ចោទឈ្មោះ [redacted] **ភូវិវុធ រួចខ្លួនពីបទចោទ** ពីបទ **ឆបោក** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាម

មាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ តាមមាត្រា ៣៥០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ ។

ហេតុដូច្នេះសម្រេច

១. ឱ្យឈ្មោះ [redacted] ភូវ៉ិធ ភេទប្រុស អាយុ ៥០ឆ្នាំ ជាតិខ្មែរ **រួចខ្លួនពីបទ រដ្ឋបាល** ប្រព្រឹត្តនៅរាជធានីភ្នំពេញ កាលពីថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០១៤ បទល្មើសដែលមានចែងឱ្យផ្តន្ទាទោសតាមមាត្រា៣៧៧ និងមាត្រា ៣៧៨ នៃក្រមព្រហ្មទណ្ឌ ។

២. សាលក្រមនេះជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី២២ ខែមករា ឆ្នាំ២០២១ កំបាំងមុខជនជាប់ចោទនិងដើមបណ្តឹង-រដ្ឋប្បវេណី និងប្រកាសជាសាធារណៈ:នៅថ្ងៃទី០៩ ខែកុម្ភៈ ឆ្នាំ២០២១ បើកសិទ្ធិប្តឹងទាស់និងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

ក្រឡាបញ្ជីសវនាការ
ហត្ថលេខានិងត្រា [redacted]

ចៅក្រមជំនុំជម្រះ
ហត្ថលេខានិងត្រា [redacted]

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម
ថ្ងៃអង្គារ ១២រោច ខែមាឃ ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ,ថ្ងៃទី ០៩ ខែកុម្ភៈ ឆ្នាំ២០២១
ក្រឡាបញ្ជី

[redacted]

បានឃើញ
ចៅក្រមជំនុំជម្រះ



[redacted]

Scanned with CamScanner